# ជំងឺ COVID-19

## Los Angeles County Department of Public Health
## កម្មវិធីជំនួយបុណ្យសពចំពោះមរណៈភាពនៃជំងឺCOVID-19 ពីFEMA

ការអនុម័តច្បាប់លើផែនការសង្គ្រោះអាមេរិកឆ្នាំ2021 ពេលនេះបានផ្តល់ជូនទៅគ្រួសារនិងបុគ្គល សម្រាប់ការចំណាយលើបុណ្យសពដោយសារជំងឺ COVID-19 នៅឆ្នាំ2021 និងជំនួយការចំណាយផ្សេងទៀតក្រៅពីពិធីបុណ្យសព ។

**លក្ខខណ្ឌសិទ្ធិទទួលបាន៖**

| **តើនរណាអាចដាក់ពាក្យបាន** | **តើនរណាដែលមិនអាចដាក់ពាក្យបាន** |
|---|---|
| • ការស្លាប់នេះត្រូវតែបានកើតឡើងនៅក្នុងសហរដ្ឋអាមេរិក រួមទាំង ទឹកដីសហរដ្ឋអាមេរិក និងតាមស្រុកនៃកូឡុំប៊ី (Columbia)។<br>• វិញ្ញាបនប័ត្រមរណៈភាព ត្រូវតែបញ្ជាក់ថាការស្លាប់នេះត្រូវបានសន្មតដោយផ្ទាល់ ឬដោយប្រយោលថាជាជំងឺ COVID-19។<br>• អ្នកស្នើសុំត្រូវតែជាពលរដ្ឋអាមេរិក មិនមែនជាពលរដ្ឋ ឬ ជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានចំណាយលើពិធីបុណ្យសពចាប់ពីថ្ងៃទី 20 មករា 2020។<br>• មិនមានតម្រូវការទាមទារចំពោះអ្នកស្លាប់ជាពលរដ្ឋអាមេរិក មិនមែន ជាពលរដ្ឋ ឬ ជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ ។ | • ចំពោះកូនជាអនីតិជនមិនអាចដាក់ពាក្យស្នើសុំក្នុងនាមមនុស្សពេញវ័យដែលបុគ្គលនោះមិនមែនជាពលរដ្ឋអាមេរិក មិនមែនជាសញ្ជាតិជាពលរដ្ឋពលរដ្ឋអាមេរិក ឬជនបរទេសដែលស្របតាមលក្ខខណ្ឌនោះទេ។<br>• មានជនបរទេសជាច្រើនប្រភេទដែលមានវត្តមាននៅសហរដ្ឋអាមេរិកដែលមិនមានសិទ្ធិទទួលបានជំនួយពី FEMA ជាលក្ខណៈបុគ្គលនិងគ្រួសារ រួមទាំងជំនួយបុណ្យសពផង។ ចំណុចទាំងនេះរួមមានដូចជា ប៉ុន្តែមិនកំណត់ត្រឹមនេះទេ៖<br>○ អ្នកកាន់ទិដ្ឋាការទេសចរណ៍បណ្តោះអាសន្ន<br>○ និស្សិតបរទេស<br>○ អ្នកកាន់ទិដ្ឋាការការងារបណ្តោះអាសន្ន<br>○ អ្នកស្រុកដែលរស់នៅជាប្រក្រតីដូចជា ពលរដ្ឋនៃរដ្ឋសហព័ន្ធ មិក្រូនេស៊ី(Micronesia) ប៉ាឡូវ(Palau) និងសាធារណរដ្ឋកោះ Marshall។ |

**របៀបដាក់ពាក្យ៖**

- ពាក្យស្នើសុំចាប់ផ្តើមទទួលចាប់ពីថ្ងៃទី 12 ខែមេសាឆ្នាំ 2021។ អ្នកដាក់ពាក្យស្នើសុំត្រូវដាក់ពាក្យតាមទូរស័ព្ទដោយទូរស័ព្ទទៅលេខ៖ 844- 684-6333 | TTY: 800-462-7585 សម្រាប់ជំនួយបុណ្យសពនៃជំងឺCOVID-19។ មិនមានទទួលពាក្យស្នើសុំតាម អនឡាញឡើយ។
- ម៉ោងធ្វើការ៖ ចន្ទ - សុក្រ, ម៉ោង 9ព្រឹក ដល់ម៉ោង 9យប់ ម៉ោងតាមភាគខាងកើត (Eastern Time)។
- ភ្នាក់ងាររៀបចំគេហដ្ឋានបុណ្យសពមិនមានសិទ្ធិដាក់ពាក្យស្នើសុំក្នុងនាមជាគ្រួសារទេ អ្នកដែលដាក់ពាក្យសុំត្រូវតែជាបុគ្គល ដែលបានចំណាយនៃពិធីបុណ្យសព ដោយមិនមែនជាអាជីវកម្មទេ។
- អ្នកដាក់ពាក្យស្នើសុំជំនួយពី FEMA សម្រាប់គេហដ្ឋាន និង/ឬការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនពីគ្រោះមហន្តរាយ ហើយក៏មានការចំណាយបុណ្យសពសម្រាប់ការស្លាប់ដោយសារជំងឺ COVID-19ផងដែរនោះ ចាប់ពីថ្ងៃទី 20 ខែមករាឆ្នាំ 2020 អាចដាក់ពាក្យសុំជំនួយបុណ្យសពដោយសារជំងឺ COVID-19ដែរ។ ពាក្យស្នើសុំផ្សេងគ្នានឹងត្រូវទាមទារជាចាំបាច់។

**ជំនួយហិរញ្ញវត្ថុ៖**

- អ្នកដាក់ពាក្យស្នើសុំអាចទទួលបានជំនួយ រីថ្លៃបុណ្យសពរបស់បុគ្គលដែលបានទទួលមរណភាពដែលមានច្រើននាក់។
- ជំនួយត្រូវបានកំណត់ត្រឹមអតិបរមាចំនួន $ 9,000 ក្នុងពិធីបុណ្យសពមួយ និងអតិបរមាចំនួន $ 35,500 សម្រាប់ការដាក់ពាក្យស្នើសុំមួយនៅតាមរដ្ឋ ទឹក ដី ឬ ស្រុកកូឡុំបៀមួយ ។
- ជាទូទៅ FEMA នឹងផ្តល់ជំនួយបុណ្យសពនៃមរណៈភាពដោយសារជំងឺ COVID-19ដល់អ្នកដាក់ពាក្យម្នាក់ប៉ុណ្ណោះ សម្រាប់បុគ្គលដែលស្លាប់ម្នាក់។ យើងទទួលស្គាល់ថាបុគ្គលជាច្រើនប្រហែលជាបានចូលរួមចំណែកក្នុងពិធីបុណ្យសព សម្រាប់បុគ្គលដែលបានចែកឋានម្នាក់។ FEMA នឹងធ្វើការជាមួយបេក្ខជនក្នុងស្ថានភាពទាំងនេះនិងអ្នកដែលដាក់វិក័យប័ត្រជាច្រើនសម្រាប់ការចំណាយបុណ្យសពនៅពេលដែលឈ្មោះរបស់ពួកគេមិនមាននៅលើបង្កាន់ដៃ។

# ជំងឺ COVID-19

## Los Angeles County Department of Public Health
## កម្មវិធីជំនួយបុណ្យសពចំពោះមរណៈភាពនៃជំងឺCOVID-19 ពីFEMA

**ការចំណាយបុណ្យសពគ្រប់គ្រងចាត់ចែងលើ៖**

- ជំនួយក្នុងពិធីបុណ្យសពចំពោះមរណៈដោយសារជំងឺC OVID-19 នឹងជួយចំណាយសម្រាប់សេវាបុណ្យសព និងការបញ្ចុះ ឬបូជាសព
- ការដឹកជញ្ជូនសម្រាប់មនុស្សរហូតដល់ទៅពីរនាក់ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលស្លាប់
- ការផ្ទេរអដ្ឋិធាតុ
- មឈូស ឬ ការរក្សាទុករបស់របរ
- គ្រោងបញ្ចុះសព ឬការបូជាសព
- សញ្ញាសម្គាល់ ឬថ្មបញ្ចុះមានឆ្លាក់ឈ្មោះ
- បព្វជិត ឬបុគ្គលិកផ្តល់សេវា
- ការរៀបចំពិធីបុណ្យសព
- ការប្រើប្រាស់សម្ភារៈ ឬបុគ្គលិកសម្រាប់ពិធីបុណ្យសព
- ការចំណាយលើការបូជា ឬការបញ្ចុះសព
- ថ្លៃដើមទាក់ទងនឹងការផលិត និងបញ្ជាក់វិញ្ញាបនប័ត្រមរណភាពដែលមានច្រើនឯកសារ
- ការចំណាយបន្ថែមដែលកំណត់ដោយរដ្ឋាភិបាលក្នុងតំបន់ ឬរដ្ឋដែលអាចអនុវត្តបានតាមច្បាប់ឬពិធីបញ្ញត្តិ

សសមាប់ព័ត៏មានបែន្ថមសូ ម https://www.fema.gov/disaster/coronavirus/economic/funeral-assistance